**សារលិខិត**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងឱកាសទិវាសន្តិភាពអន្តរជាតិ**
**ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៩**

សូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

ជនរួមជាតិជាទីស្នេហា

**ទិវាសន្តិភាពអន្តរជាតិ** ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៥៥ នាឆ្នាំ២០០១ ដើម្បីលុបបំបាត់អំពើហិង្សា បញ្ឈប់សង្គ្រាម ជំរុញឱ្យមានសុខសន្តិភាពក្នុងប្រទេស ក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោកទាំងមូល ត្រូវបានប្រារព្ធទូទាំងពិភពលោកនៅថ្ងៃទី២១ ខែកញ្ញា ជារៀងរាល់ឆ្នាំ។

ដោយសន្តិភាពមានតម្លៃពិតជាពុំអាចកាត់ថ្លៃបាន និងមានសារៈសំខាន់ជាចំបងសម្រាប់មនុស្សជាតិ ក៏ដូចជាប្រទេសជាតិ កម្ពុជាមានសេចក្តីសោមនស្សរីករាយ ចូលរួមជាមួយពិភពលោកប្រារព្ធនូវ **ទិវាសន្តិភាពអន្តរជាតិ** នៅថ្ងៃទី២១ ខែកញ្ញានេះ ដើម្បីលើកកម្ពស់ការយល់ដឹងពីអត្ថន័យនៃសន្តិភាពឱ្យកាន់តែទូលំទូលាយ ខិតខំពង្រឹងសាមគ្គីភាព ឯកភាពជាតិ បន្តជំរុញស្មារតីនិងពួតដៃគ្នាជាធ្លុងមួយថែរក្សាឱ្យបានគង់វង្សនូវសុខសន្តិភាពយូរអង្វែងសម្រាប់កម្ពុជាយើង និងពិភពលោក ដែលនេះជាសេចក្តីប្រាថ្នារបស់មនុស្សជាតិ និងជាមូលដ្ឋានគ្រឹះចាំបាច់សម្រាប់ប្រទេស ដើម្បីបោះជំហានបន្តទៅមុខលើវិថីអភិវឌ្ឍន៍ និងការរីកចម្រើន។

ជនរួមជាតិជាទីស្នេហា

ការវិវត្តន៍ដ៏ស្មុគស្មាញមិនអាចប៉ាន់ប្រមាណជាមុន នៃសភាពការណ៍ជុំវិញពិភពលោកនាពេលកន្លងមក និងបច្ចុប្បន្ន ជាពិសេសការប្រកួតប្រជែងរវាងមហាអំណាច ក្នុងការការពារផលប្រយោជន៍នយោបាយ សេដ្ឋកិច្ច និងយោធា បាននិងកំពុងនាំមកនូវការគំរាមកំហែង ចំពោះសន្តិភាពដែលនៅតែមានភាពស្រួចស្រាវទាំងក្នុងកម្រិតតំបន់ និងសកល។ ទន្ទឹមនេះ សន្តិភាពរបស់កម្ពុជាក៏ស្ថិតនៅក្នុងលក្ខណៈផុយស្រួយ ដោយសារតែមានការគំរាមកំហែង និងការបន្តយាយី និងអន្តរាគមន៍ចូលកិច្ចការផ្ទៃក្នុងឥតឈប់ឈរពីមជ្ឈដ្ឋានខាងក្រៅ ជាពិសេសពីបណ្តាប្រទេសមហាអំណាច និងប្រទេសលោកខាងលិចមួយចំនួន។ ទោះបីកម្ពុជាស្ថិតនៅក្រោមសម្ពាធនៃការគំរាមកំហែងដាក់ទណ្ឌកម្ម ក្រោមលេសប្រជាធិបតេយ្យ និងសិទ្ធិមនុស្សយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជា នៅតែស្ថិតនៅរួមសុខរួមទុក្ខជាមួយប្រជាជនក្នុងគ្រប់កាលៈទេសៈ រួបរួមសាមគ្គី ឯកភាពជាតិ ការពារសមិទ្ធិផលសង្គមជាតិ កសាងនិងរក្សាការពារឯករាជ្យ សេរីភាពប្រជាធិបតេយ្យ អព្យាក្រឹត្យ និងវឌ្ឍនភាពសង្គម និងប្រកាន់ខ្ជាប់នូវឆន្ទៈមោះមុតក្នុងការរក្សាសន្តិភាព និងស្ថិរភាពឱ្យខានតែបានទោះស្ថិតក្នុងតម្លៃណាក៏ដោយ។

បន្ទាប់ពីការរំដោះប្រទេសជាតិបានជោគជ័យពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ និងការនាំមកនូវសន្តិភាពពេញលេញពេញផ្ទៃប្រទេសនៅឆ្នាំ ១៩៩៨ ក្រោមគោលនយោបាយ

ឈ្នះ-ឈ្នះ សន្តិភាព ស្ថិរភាព និងសុខមាលភាពប្រជាជន ត្រូវបានចាត់ទុកជាអាទិភាពខ្ពស់បំផុតនៃយុទ្ធសាស្ត្រនយោបាយរបស់រាជរដ្ឋាភិបាល។ ជានិមិត្តរូបនៃឧត្តមគតិដ៏ថ្លៃថ្លានេះ រាជរដ្ឋាភិបាលកម្ពុជាបានកសាងវិមានឈ្នះ-ឈ្នះ ដើម្បីរំលឹកពីវីរភាពនៃការលះបង់សាច់ស្រស់ឈាមស្រស់ ក្នុងការរំដោះប្រទេសជាតិឱ្យរួចផុតពីរបបខ្មៅងងឹត និងប្រល័យពូជសាសន៍។ ជាមួយគ្នានេះ វិមានឈ្នះ-ឈ្នះ ក៏បានបង្ហាញឱ្យឃើញពីមោទនភាពជាតិ ចំពោះជោគជ័យដ៏ត្រចះត្រចង់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការកសាង និងការពារសន្តិភាព ស្ថិរភាព និងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ។ ដោយមានការយល់ដឹងពីតម្លៃនៃសន្តិភាពដែលទទួលបានដោយលំបាកនេះហើយ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដាច់ខាតការពារខឿនឯករាជ្យភាព អធិបតេយ្យភាព បូរណភាពដែនដី និងម្ចាស់ជោគវាសនារបស់ខ្លួន។

កម្ពុជា ដែលពីមុនបានឆ្លងកាត់ភ្លើងសង្គ្រាមពីឆ្នាំ១៩៧០-១៩៧៥ និងធ្លាក់ក្នុងគ្រោះមហន្តរាយប្រល័យពូជសាសន៍ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឥឡូវបានក្លាយទៅជាប្រទេសមួយដែលគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ការបោះឆ្នោតដែលបានប្រព្រឹត្តទៅប្រកបដោយលក្ខណៈសេរីត្រឹមត្រូវ និងយុត្តិធម៌ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានឆ្លុះបញ្ចាំងឱ្យឃើញពីភាពចាស់ទុំនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងពីភាពជាម្ចាស់អំណាចពិតប្រាកដរបស់ប្រជាជនកម្ពុជា។ ការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្សនៅក្នុងក្របខ័ណ្ឌច្បាប់ និងសមស្របតាមប្រពៃណី ទំនៀមទំលាប់ អរិយធម៌របស់ប្រទេសជាតិ ជាមូលដ្ឋានគ្រឹះសំខាន់រួមចំណែកដល់ការការពារនិរន្តរភាពសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រទេសជាតិប្រកបដោយបរិយាប័ន្ន ដែលជាបំណងប្រាថ្នាដ៏ទទូចរបស់ប្រជាជនកម្ពុជា។

## ជនរួមជាតិជាទីស្នេហា

ក្រោមម្លប់សន្តិភាពនេះហើយ ដែលកម្ពុជាចាប់ផ្តើមមានកម្លាំងសេដ្ឋកិច្ច ងើបផុតចេញពីឋានៈជាប្រទេសដែលមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបជាផ្លូវការក្នុងឆ្នាំ ២០១៦។ កម្ពុជាក៏មានចក្ខុវិស័យវែងឆ្ងាយ ក្នុងការពន្លឿនពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ការលើកកម្ពស់សមត្ថភាពការប្រកួតប្រជែង ការបង្កើនផលិតភាព និងតម្លៃបន្ថែមក្នុងប្រព័ន្ធខ្សែចង្វាក់តម្លៃសកល និងបង្កើនភាពធន់នឹងវិបត្តិ ដើម្បីប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។ យើងមានមោទនភាព ដែលកម្ពុជាមានកំណើនសេដ្ឋកិច្ចជាង **៧%** ប្រកបដោយបរិយាប័ន្ន និងសមធម៌ ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ។ ជាតុផ្សំនៃសន្តិភាព អត្រាកំណើនសេដ្ឋកិច្ចខ្ពស់ រួមផ្សំនឹងការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ជាតិដ៏ត្រឹមត្រូវក្រោមយុទ្ធសាស្ត្រចតុកោណ បានធ្វើឱ្យអត្រានៃភាពក្រីក្ររបស់ប្រជាជនខ្មែរថយចុះយ៉ាងគំហុកពី ៥៣.២% ក្នុងឆ្នាំ ២០០៤ មកនៅក្នុងរង្វង់ ១០% នាពេលបច្ចុប្បន្ន។

## ជនរួមជាតិជាទីស្នេហា

កម្ពុជាមានមោទនភាពក្រៃលែង ដែលបានប្រែក្លាយបទពិសោធន៍ដ៏ល្វីងជូរចត់នៃសង្គ្រាមស៊ីវិលឱ្យទៅជាការចូលរួមចំណែកយ៉ាងសកម្ម ក្នុងបុព្វហេតុសន្តិភាពពិភពលោក។ កម្ពុជាបានប្រែក្លាយខ្លួនពីប្រទេសដែលធ្លាប់បានទទួលកងកំលាំងរក្សាសន្តិភាពអង្គការសហប្រជាជាតិ ទៅជាប្រទេសដែលបាន នឹងកំពុងបញ្ជូនកងកំលាំងជាបន្តបន្ទាប់ ចូលរួមបេសកកម្មរក្សាសន្តិភាពទៅបណ្តាប្រទេសនានា ដែល

កំពុងស្ថិតនៅក្នុងភ្លើងសង្គ្រាម។ ចាប់តាំងពីឆ្នាំ ២០០៦ ដល់បច្ចុប្បន្ន កម្ពុជាបានបញ្ជូនកងកម្លាំងចំនួន ៦៣៥១ នាក់ (ស្ត្រីចំនួន ៣២៦ នាក់) ទៅចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់ អ.ស.ប. ក្នុងប្រទេសចំនួន ៨ រួមមានប្រទេស ស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ អាហ្វ្រិកកណ្ដាល លីបង់ ស៊ីប ស៊ីរី និងម៉ាលី។ ទោះបីជាបេសកកម្មទាំងនេះជា បេសកកម្មប្រកបដោយហានិភ័យ និងគ្រោះថ្នាក់ក៏ដោយ កងទ័ពកម្ពុជាដែលកំពុងបំពេញបេសកកម្មនៅតាមចំណុចក្តៅបំផុតនោះ នៅតែមានឆន្ទៈមោះមុតក្នុងការបន្តរួមចំណែកជួយសង្គ្រោះប្រទេសដទៃឱ្យទទួលបានសន្តិភាព និងចាកផុតពីទុក្ខវេទនានៃសង្គ្រាម និងការបំផ្លិចបំផ្លាញ។

កម្ពុជាក៏នឹងបន្តចូលរួមចំណែកក្នុងការការពារសន្តិភាព ស្ថិរភាព និងសន្តិសុខពិភពលោក តាមរយៈការចូលរួមកិច្ចសហប្រតិបត្តិការរបស់យើង ក្នុងការប្រយុទ្ធដោះស្រាយការប្រឈមនានានៅលើសកលលោក តួយ៉ាងប្រឆាំងនឹងភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការប្រែប្រួលធាតុអាកាស ការជួញដូរគ្រឿងញៀន និងជំងឺឆ្លង។ល។

ដោយផ្តោតសារៈសំខាន់លើស្នាដៃ និងការរួមចំណែកទាំងអស់នេះ កម្ពុជាត្រូវបានផ្តល់ទំនុកចិត្តដោយសហគមន៍អន្តរជាតិ ឱ្យកាន់តួនាទីសំខាន់ចំនួនបីក្នុងឆាកអន្តរជាតិ។ ទី ១ គឺឋានៈជាអនុប្រធានមហាសន្និបាត អ.ស.ប. សម្រាប់ឆ្នាំ ២០១៨-២០១៩ ទី ២ គឺឋានៈជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម អ.ស.ប. សម្រាប់អាណត្តិឆ្នាំ ២០១៩ និងទី ៣ គឺឋានៈជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុបលើកទី ១៣ នៅឆ្នាំ ២០២០ ខាងមុខនេះ។ តួនាទីទាំងនេះ នឹងផ្តល់លទ្ធភាពកាន់តែច្រើនដល់កម្ពុជាក្នុងការចូលរួមចំណែកដល់បុព្វហេតុ នៃការរក្សាសន្តិភាព និងលើកកិត្យានុភាពកម្ពុជាលើឆាកអន្តរជាតិ។

មុននឹងបញ្ចប់ ទូលព្រះបង្គំខ្ញុំ សូមអំពាវនាវដល់ជនរួមជាតិទាំងអស់ បន្តចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការលើកស្ទួយសន្តិភាពជាតិ និងអន្តរជាតិ ដោយបន្តថែរក្សានិងការពារសន្តិភាពដែលមានស្រាប់ ពង្រឹងឯកភាពជាតិ អនុវត្តវប្បធម៌សន្ទនា គោរពច្បាប់ ដោះស្រាយបញ្ហាដោយសន្តិវិធី និងទប់ស្កាត់រាល់ឧបាយកល និងការប៉ុនប៉ងតាមគ្រប់រូបភាពដែលមានគោលបំណងធ្វើឱ្យប្រទេសជាតិធ្លាក់ក្នុងសភាពវឹកវរ និងអស្ថិរភាព។

ខ្ញុំសូមប្រសិទ្ធពរជូនជនរួមជាតិជាទីស្នេហា សូមបានប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ សៅរ៍ ៨រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៩

**ហ៊ុន សែន**